**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០៣ .សរណន**

# សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១២២ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៨

ទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ ដែលចាប់ផ្តើមនាឆ្នាំ១៨៨៦ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនៃលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់ប្រជាពលករ។ នៅកម្ពុជា ទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំតាំងពីឆ្នាំ១៩៧៩ ហើយមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានកំណត់យកថ្ងៃទី១ ខែឧសភា ជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការ និងកម្មករនិយោជិតទាំងអស់ ដូចថ្ងៃបុណ្យជាតិ បុណ្យប្រពៃណី និងបុណ្យអន្តរជាតិនានាដែរ។ ជារៀងរាល់ឆ្នាំ មានស្ថាប័នរដ្ឋ និងសហគ្រាស គ្រឹះស្ថានឯកជនជាច្រើនបានរៀបចំអបអរសាទរ និងប្រារព្ធទិវានេះ ក្នុងបរិយាកាសសប្បាយរីករាយ និងសាមគ្គីភាព គួរឱ្យកត់សំគាល់។

យើងទាំងអស់គ្នាត្រូវឧទ្ទិស ទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ ២០០៨នេះ ជាទិវាដើម្បីទស្សនវិស័យថ្មីមួយ គឺ ***បង្កើនផលិតភាពការងារ ដើម្បីលក្ខខណ្ឌការងារល្អប្រសើរ និងការប្រកួតប្រជែង*** សំដៅធានាការអភិវឌ្ឍសិទ្ធិ និងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធក្នុងសង្គម ស្របតាមច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិខាងការងារ។

អាស្រ័យហេតុនេះ ដើម្បីរៀបចំការប្រារព្ធខួបលើកទី ១២២ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៨ នេះ ប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដូចខាងក្រោមនេះ :

១-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចេញសេចក្តីជូនដំណឹងដល់មន្ទីរខេត្ត-ក្រុងក្រោមឱវាទ អង្គការវិជ្ជាជីវៈរបស់និយោជក អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ម្ចាស់និងនាយកក្រុមហ៊ុន ព្រមទាំងកម្មករនិយោជិត ដើម្បីណែនាំអំពីការឈប់សម្រាក និងបំផុសការជួបសំណេះសំណាល ការជួបជុំជប់លៀងកំសាន្តសប្បាយ ការដើរកំសាន្តតាមរូបភាពនិងលទ្ធភាពរៀងៗខ្លួនរបស់សហគ្រាសគ្រឹះស្ថានសំដៅបង្កបរិយាកាសសាមគ្គីភាព ភាតរភាពរវាងកម្មករនិយោជិត និងនិយោជក។ ជាពិសេស ចៀសវាងការប្រើប្រាស់រូបភាពទិវាពលកម្មអន្តរជាតិ ដើម្បីធ្វើសកម្មភាពដែលបណ្តាលឱ្យមានការប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈរបស់សង្គម។

ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវជ្រើសរើសរោងចក្រជានិមិត្តរូប ដើម្បីចូលរួមកម្មវិធីកំសាន្ត សប្បាយរីករាយ និងធ្វើការសំណេះសំណាលជាមួយកម្មករនិយោជិត ។

២-ក្រសួងព័ត៌មាន ត្រូវណែនាំប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជនទទួលផ្សព្វផ្សាយ សារលិខិតរបស់សម្តេចមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ១២២ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៨ ឱ្យបានទូលំទូលាយ ។

៣-ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរខេត្តក្រុង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវមានវិធានការតាមសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ក្នុងឱកាសទិវាពលកម្មអន្តរជាតិ ឆ្នាំ២០០៨ នេះ ។

៤-ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំឱ្យមានកម្មវិធីសំណេះសំណាល និងផ្សព្វផ្សាយសារលិខិតរបស់សម្តេចមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ១២២ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៨ និងណែនាំឱ្យមានការចងបដា ពាក្យស្លោក នៅតាមដងវិថីសំខាន់ៗ នៅតាមក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងសហគ្រាសគ្រឹះស្ថានឯកជន គ្រប់ខេត្ត-ក្រុង ។ ដោយឡែក រាជធានីភ្នំពេញដែលជាមជ្ឈមណ្ឌលប្រមូលផ្តុំ និន្នាការនយោបាយ អង្គការអន្តរជាតិគ្រប់ ប្រភេទ និងមានសហគ្រាសគ្រឹះស្ថានច្រើនកុះករនោះ ត្រូវជ្រើសរើសដងវិថីសំខាន់ៗ និងទីតាំងរោងចក្រ សហគ្រាស ដើម្បីធ្វើការចងបដា ពាក្យស្លោក ។

៥-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយថវិកា ឱ្យបានទាន់ពេលវេលា និងតាមគោលការណ៍កំណត់ ដើម្បីធានាការចាត់ចែងដំណើរការរៀបចំសមស្របតាមគោលបំណង និងសំណូមពរ ។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ កម្មករនិយោជិតកម្ពុជា និងពលករបរទេសទាំងអស់ ចូលរួមអបអរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៨ ក្នុងក្តីសោមនស្សរីករាយ សាមគ្គីភាព និងភាតរភាព ដើម្បីឱ្យស័ក្តិសមជាបុណ្យការងាររបស់ប្រទេសជាតិយើង ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរ គ្រប់ខេត្ត ក្រុង រៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និងខេត្ត ក្រុង
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ឯកសារ-កាលប្បវត្តិ